**នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 02-Nov-2012, 13:39
CMS/CFO: Uch Arun

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ២០១២

ភាគីដាក់ឯកសារ: សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: បារាំង/បកប្រែជាភាសាខ្មែរ

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើសុំរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីដើម្បីកំណត់អំពីវិសាលភាពនៃសក្ខីកម្មស្តី ពីការឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានដាក់សំណើសុំ**

---

**ដាក់ដោយ៖**

**សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Elisabeth SIMONNEAU-FORT

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី

ហុង គឹមសួន

គឹម ម៉េងឃី

ឡោ ជុនធី

**នៅចំពោះមុខ៖**

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យូរ ឧត្តរា

**ផ្ញើជូន៖**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

ម៉ុច សុវណ្ណារី

ស៊ិន សុវ៉ន

សំ សុគង់

វ៉េន ពៅ

ទី ស្រីនណា

Emmanuel ALTIT
Pascal AUBOIN
Patrick BAUDOIN
Evelyne BOILEAU-BRANDOMIR
Philippe CANONNE
Annie DELAHAIE
Laure DESFORGES
Ferdinand DJAMMEN NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Daniel LOSQ
Christine MARTINEAU
Mahdev MOHAN
Barnabé NEKUIE
Lyma Thuy NGUYEN
Elisabeth RABESANDRATANA
Julien RIVET
Fabienne TRUSSES NAPROUS
Nushin SARKARATI
Philippine SUTZ
Beini YE

ជា លាង

Andrew T. CAYLEY

យ៉េត ចរិយា

William SMITH

**<u>ជនជាប់ចោទ៖</u>**

ខៀវ សំផន

អៀង សារី

អៀង ធីរិទ្ធ

នួន ជា

**<u>សហមេធាវីការពារក្តី៖</u>**

សុន អរុណ

Michiel PESTMAN
Victor KOPPE
Jasper PAUW
Andrew IANUZZI

អាង ឧត្តម

Michael G. KARNAVAS

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN
Jacques VERGES

ផាត់ ពៅស៊ាង

Diana ELLIS

**<u>សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖</u>**

Silke STUDZINSKY
Marie GUIRAUD
Olivier BAHOUGNE

# I. ការរំលឹកអំពីនីតិវិធី

១. ចាប់តាំងពីដំណើរការជំនុំជម្រះមក ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ៦ រូប ត្រូវបានស្ដាប់យកចម្លើយដោយអង្គជំនុំជម្រះ និងត្រូវបានអនុញ្ញាតឲ្យផ្ដល់សក្ខីកម្មស្ដីអំពីការឈឺចាប់របស់ខ្លួន[1]។

២. នាសវនាការថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ បន្ទាប់ពីមានការលើកឡើងមួយរបស់សហមេធាវីជាតិនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីពាក់ព័ន្ធទៅនឹងបញ្ហានេះ កិច្ចពិភាក្សាស្ដីអំពីវិសាលភាពនៃការផ្ដល់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីពាក់ព័ន្ធទៅនឹងការឈឺចាប់ដែលពួកគេបានទទួលរង ត្រូវបានធ្វើឡើង។ អង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាតឲ្យសហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី និងសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ដាក់នូវសំណើសុំរបស់ខ្លួនជាលាយលក្ខអក្សរស្ដីអំពីវិសាលភាពពិតប្រាកដ នៃសក្ខីកម្មពាក់ព័ន្ធទៅនឹងការឈឺចាប់ដែលដើមបណ្ដឹងរដ្ឋប្បវេណីបានទទួលរង[2]។

៣. សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី និងសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូង ធ្វើការរំលឹកអំពីវិសាលភាពទូលំទូលាយនៃសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីស្ដីអំពីការឈឺចាប់ដែលពួកគេបានទទួលរង និងគូសបញ្ជាក់នូវវិធានមួយចំនួន និងគោលការណ៍ជាសារវន្តពាក់ព័ន្ធទៅនឹងលក្ខណៈសម្បត្តិ និងការប្រតិបត្តិចំពោះដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងអំឡុងពេលសវនាការ ដើម្បីជៀសវៀងនូវបញ្ហាផ្នែកនីតិវិធីដែលចោទឡើងច្រំដែលៗ និងគ្មានមូលដ្ឋានច្បាប់ នាពេលអនាគត។

---

[1] ដើមបណ្ដឹងរដ្ឋប្បវេណីលេខ TCCP-123 សក្ខីកម្មធ្វើនៅចំពោះមុខអង្គជំនុំជំរះនៅថ្ងៃទី៧ ខែធ្នូ និងថ្ងៃទី១០ ខែមករា ឆ្នាំ២០១២ ដើមបណ្ដឹងរដ្ឋប្បវេណីលេខ TCCP-185 សក្ខីកម្មធ្វើនៅចំពោះមុខអង្គជំនុំជំរះនៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១១ និងថ្ងៃទី១០ និង១១ មករា ដើមបណ្ដឹងរដ្ឋប្បវេណីលេខ TCCP-28 សក្ខីកម្មធ្វើនៅចំពោះមុខអង្គជំនុំជំរះនៅថ្ងៃទី២៨ និង ២៩ សីហា ដើមបណ្ដឹងរដ្ឋប្បវេណីលេខ TCCP-169 សក្ខីកម្មធ្វើនៅចំពោះមុខអង្គជំនុំជំរះនៅថ្ងៃទី១៩ និង២២ ខែតុលា ឆ្នាំ ២០១២ ដើមបណ្ដឹងរដ្ឋប្បវេណីលេខ TCCP-25 សក្ខីកម្មធ្វើនៅចំពោះមុខអង្គជំនុំជំរះនៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ ដើមបណ្ដឹងរដ្ឋប្បវេណីលេខ TCCP-64 សក្ខីកម្មធ្វើនៅចំពោះមុខអង្គជំនុំជំរះនៅថ្ងៃទី២៣ និង ២៤ ខែតុលា ឆ្នាំ២០១២។

[2] E1/XXX ប្រតិចារិកអង្គសវនាការថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ ទំព័រ ១៧ បន្ទាត់ទី ១៤ ដល់ ១៨។ *សំណើសុំរបស់សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីដើម្បីកំណត់អំពីវិសាលភាពនៃសក្ខីកម្មស្ដីពីការឈឺចាប់របស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលបានដាក់សំណើសុំ*

## II. ទន្និក្ខករណ៍

៤. សហមេធាវីនាំមុខ និងសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី សូមរំលឹកដល់ភាគីថា យោងទៅលើវិធានអនុវត្តនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ "ជនរងគ្រោះ" គឺជារូបវន្តបុគ្គលដែលបានទទួលរងព្យសនកម្មបណ្ដាលមកពីឧក្រិដ្ឋកម្មដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក.[3]។ ផ្អែកលើវិធាន និងគោលការណ៍ច្បាប់អន្តរជាតិ[4] បុគ្គលម្នាក់អាចត្រូវបានចាត់ទុកថាជាជនរងគ្រោះ "ទោះបីជាជនល្មើស ត្រូវបានគេកំណត់ ឬពុំត្រូវបានគេកំណត់អត្តសញ្ញាណ ត្រូវបានចាប់ខ្លួន ចោទប្រកាន់ ឬប្រកាសថាជាពិរុទ្ធជនក៏ដោយ[5]"។

៥. ចំណែកឯ "ដើមបណ្ដឹងរដ្ឋប្បវេណី" ត្រូវបានកំណត់និយមន័យដោយអង្គជំនុំជម្រះវិសាមញ្ញថាជាជនរងគ្រោះ ដែលពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់គេត្រូវបានទទួលយកដោយសហចៅក្រមស៊ើបអង្កេត[6]។

៦. ដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួនក្នុងចំណោមដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ ដែលបានចូលរួមក្នុងដំណើរការជំនុំជម្រះលើកទីមួយលើសំណុំរឿង ០០២ ត្រូវបានទទួលយកតាមរយៈសេចក្ដីសម្រេច

---

[3] **សេចក្ដីណែនាំអនុវត្តន៍ ២០០៧/០២/វិសោធនកម្មលើកទី ១** ៖ ការចូលរួមរបស់ជនរងគ្រោះ មាត្រា ៣.២។

[4] សេចក្ដីសម្រេចលេខ ៤០/៣៤ របស់មហាសន្និបាតអង្គការសហប្រជាជាតិ ឆ្នាំ ១៩៨៥ សេចក្ដីប្រកាសស្ដីអំពីគោលការណ៍ច្បាប់ជាសារវន្តពាក់ព័ន្ធនិងជនរងគ្រោះនៃអំពើឧក្រិដ្ឋកម្ម និងជនរងគ្រោះនៃការរំលោភអំណាច មាត្រា ២។ សេចក្ដីសម្រេចលេខ ៦០/១៤៧ របស់មហាសន្និបាតអង្គការសហប្រជាជាតិ ឆ្នាំ ២០០៥ គោលការណ៍ជាសារវន្ត និងសេចក្ដីណែនាំពាក់ព័ន្ធនិងសិទ្ធិធ្វើបណ្ដឹង និងទទួលបានការជួសជុលសំណង របស់ជនរងគ្រោះនៃទង្វើរំលោភបំពានជាក់ស្ដែងលើនីតិអន្តរជាតិនៃសិទ្ធិមនុស្ស និងការរំលោភធ្ងន់ធ្ងរលើនីតិមនុស្សធម៌អន្តរជាតិ មាត្រា V។ សេចក្ដីសម្រេចលេខ ២០០៥/២០ របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច របស់អង្គការសហប្រជាជាតិ ឆ្នាំ ២០០៥ មាគ៌ាណែនាំលើវិស័យច្បាប់ ក្នុងរឿងក្ដីដែលពាក់ព័ន្ធដែលមានជនរងគ្រោះ និងសាក្សីនៃអំពើល្មើស ជាកុមារ។ មាត្រា IV,9.a។

[5] សេចក្ដីសម្រេចលេខ ៤០/៣៤ របស់មហាសន្និបាតអង្គការសហប្រជាជាតិ សេចក្ដីប្រកាសស្ដីអំពីគោលការណ៍ច្បាប់ជាសារវន្តពាក់ព័ន្ធនិងជនរងគ្រោះនៃអំពើឧក្រិដ្ឋកម្ម និងជនរងគ្រោះនៃការរំលោភអំណាច មាត្រា ២។

[6] វិធាន ២៣ ស្ទួន ១ នៃវិធានផ្ទៃក្នុង។

របស់សហចៅក្រមស៊ើបអង្កេត ហើយមួយចំនួនទៀតត្រូវបានទទួលយកតាមរយៈសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ ដោយអនុវត្តតាមវិធាន ២៣ ស្ទួន (២) និង (៣) នៃវិធានផ្ទៃក្នុង[7]។

៧. ជាក់ស្ដែង ជនរងគ្រោះទាំងនេះ ដែលបានលើកនូវភស្តុតាងសមហេតុសមផលគួរឲ្យជឿជាក់បានភ្លាមថា ព្យសនកម្មដែលពួកគេបានទទួលរង គឺជាលទ្ធផលដោយផ្ទាល់នៃអង្គហេតុទាំងឡាយដែលត្រូវបានចោទប្រកាន់ក្នុងសំណុំរឿង ដូចដែលបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយ ត្រូវបានទទួលស្គាល់ថាជាដើមបណ្ដឹងរដ្ឋប្បវេណី។

៨. នៅក្នុងដំណាក់កាលនេះ គេត្រូវបង្ហាញអំពីភាពខុសគ្នារវាងជនរងគ្រោះដែលបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីយោងតាមវិធាន ២៣ ស្ទួន នៃវិធានផ្ទៃក្នុង និងជនរងគ្រោះដែលគ្រាន់តែបានដាក់ពាក្យបណ្ដឹងទៅកាន់សហព្រះរាជអាជ្ញាស្របតាមវិធាន ៤៩.២ នៃវិធានផ្ទៃក្នុង ដែលពួកគេទាំងនេះគ្រាន់តែជាអ្នកប្ដឹងធម្មតាប៉ុណ្ណោះ។

៩. សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី និងសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី សូមរំលឹកថាព្យសនកម្មដែលជនរងគ្រោះបានទទួលរង បានធ្វើជាកម្មវត្ថុនៃសេចក្ដីសម្រេចរបស់តុលាការ ដោយសហចៅក្រមស៊ើបអង្កេតរួចទៅហើយ។ ដើមបណ្ដឹងរដ្ឋប្បវេណីមិនមានអ្វីត្រូវលើកឡើងអំពីព្យសនកម្មនៅក្នុងដំណាក់កាលនេះនៃនីតិវិធីទៀតទេ ព្យសនកម្មដែលជាមូលដ្ឋាននៃភាពដែលអាចទទួលយកបាននៃបណ្ដឹងរបស់គេនោះ។

## សិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការបង្ហាញអំពីការឈឺចាប់របស់ខ្លួន

១០. សិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការលើកឡើងអំពីភាពឈឺចាប់ដែលខ្លួនទទួលរង គឺជាសិទ្ធិដែលមិនអាចកាត់ផ្ដាច់បានអំពីលក្ខណៈសម្បត្តិជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល។ សិទ្ធិ

---

[7]សូមអានដីកាផ្សេងៗដែលចេញដោយសហចៅក្រមស៊ើបអង្កេតពាក់ព័ន្ធនិងភាពដែលអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី D403, D404, D406, 408, 409, D410, D411, D412, D413, D415...។ល។ និងសេចក្ដីសម្រេចពាក់ព័ន្ធនិងបណ្ដឹងឧទ្ធរណ៍ប្រឆាំងទៅនិងដីការបស់សហចៅក្រមស៊ើបអង្កេតលើភាពដែលអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី D404/2/4។

នេះអនុញ្ញាតឱ្យពន្លេចឡើង នៅក្នុងអំឡុងនៃកិច្ចពិភាក្សាដេញដោល អំពីការប៉ះទង្គិចទៅលើបុគ្គលមនុស្សពីសំណាក់អង្គហេតុដែលបានចោទប្រកាន់។ លទ្ធផលដែលបង្កឡើងដោយអំពើល្មើសទៅលើមនុស្ស គឺជាមូលដ្ឋានដែលកំណត់ភាពធ្ងន់ធ្ងរនៃចំណាត់ថ្នាក់បទល្មើស និងការចោទប្រកាន់ ដែលបានធ្វើក្រៅអំពីមូលដ្ឋានដែលផ្អែកលើពិរុទ្ធភាពនៃជនល្មើស។

១១. ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិក្នុងការនិយាយអំពីការឈឺចាប់របស់ខ្លួននៅពេលបញ្ចប់កិច្ចស៊ើបសួរ ចំណុចនេះមិនត្រូវច្រឡំគ្នាជាមួយព្យសនកម្មដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរងទេ។

១២. ការឈឺចាប់ ដែលត្រូវបានកំណត់និយមន័យនៅក្នុងវចនានុក្រមថាជា "ការឈឺចាប់ជាស្ថានភាពអូសបន្លាយនៃការឈឺចាប់ផ្លូវកាយ ឬផ្លូវចិត្ត"[8]។ ការឈឺចាប់គឺជាស្ថានភាពខាងផ្លូវកាយ និង/ឬ ផ្លូវចិត្តដែលបង្កឡើងដោយព្យសនកម្មនានាដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរង។ ស្ថានភាពដែលមានលក្ខណៈជាបុគ្គលនេះ អាចមានលក្ខណៈខុសៗគ្នា អាស្រ័យទៅលើបុគ្គលដែលពាក់ព័ន្ធ។ វាមិនអាចទៅរួចទេ ក្នុងការដែលជនរងគ្រោះនៃអង្គហេតុដែលកើតឡើងបន្តបន្ទាប់គ្នា ធ្វើការជ្រៀកការឈឺចាប់របស់ខ្លួនជា ជម្រៀកៗ ទៅតាមសម័យកាល ឬទៅតាមបច្ចេកទេសនានានោះ។ ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចធ្វើការផ្សារភ្ជាប់ការឈឺចាប់ជាក់លាក់របស់ខ្លួនមួយផ្នែកទៅនឹងព្រឹត្តិការណ៍ណាមួយបានទេ នៅខណៈដែលព្រឹត្តិការណ៍ទាំងនោះបានកើតឡើងបន្តបន្ទាប់គ្នា ឬជាដំណាក់កាលៗនៅក្នុងឆាកជីវិតរបស់គាត់ នោះ។ ប្រសិនណាជាករណីដូច្នោះមែន លទ្ធផលមានលក្ខណៈជាសប្បនិមិត្តប៉ុណ្ណោះ ហើយមិនបានលាតត្រដាងអំពីការឈឺចាប់ពិតប្រាកដដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរងឡើយ។ ការឈឺចាប់ គឺជាស្ថានភាពផ្លូវកាយ និងផ្លូវចិត្តទាំងមូល ដែលគេមិនអាច "ធ្វើការជ្រៀកជាជម្រៀកតូចៗដូច សាច់ក្រកបានឡើយ" នេះបើយោងតាមប្រសាសន៍របស់លោកចៅក្រម Lavergne ដែលបានពោល ក្នុងអំឡុងសវនាការថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ ពាក់ព័ន្ធទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី[9]។

---

[8] វចនានុក្រម Larousse / http://www.larousse.com/en/dictionaries/french/souffrance/

[9] **E1/XXX** ប្រតិចារិកអង្គសវនាការថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ ទំព័រ ៦៩ បន្ទាត់ទី ១១។

១៣. ផ្អែកលើចក្ខុវិស័យរបស់អ្នកជំនាញខាងចិត្តវិទ្យា និងវិកលវិទ្យា មានការប៉ះទង្គិចមួយដែលមានលក្ខណៈ "បូកបញ្ចូលគ្នា" ពោលគឺជាការប៉ះទង្គិចដែលកើតឡើងក្នុងពេលវេលាដែលអូសបន្លាយ ហើយកើតចេញពីព្រឹត្តិការណ៍ជាច្រើនដែលកើតឡើងបន្តបន្ទាប់គ្នា[10]។

## ផ្អែកលើចក្ខុវិស័យនៃនីតិវិធី

១៤. បន្ទាប់ពីមានសេចក្តីសម្រេចស្តីពីការបំបែកសំណុំរឿង ០០២[11] សហមេធាវីនាំមុខ និងសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានកត់សម្គាល់ឃើញថា ក្នុងការអនុវត្តជាក់ស្តែង វាពុំអាចទៅរួចទេ ក្នុងការដែលដើមបណ្តឹងរដ្ឋប្បវេណី នៅខណៈដែលខ្លួនមានឱកាសលើកឡើងអំពីការឈឺចាប់របស់ខ្លួននៅចំពោះមុខអង្គជំនុំជម្រះ ធ្វើការកំណត់ និងជ្រើសរើសជាបឋម នូវព្យសនកម្មដែលពាក់ព័ន្ធតែទៅនឹងឧក្រិដ្ឋកម្មទាំងឡាយដែលកើតមានឡើងក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ដែលជាផ្នែកនៃការជំនុំជម្រះលើកទីមួយលើសំណុំរឿង ០០២ នេះ ហើយបន្ទាប់មកធ្វើការបង្ហាញការឈឺចាប់របស់ខ្លួនដែលពាក់ព័ន្ធតែទៅនឹងព្យសនកម្មទាំងនេះ នោះ។

១៥. តាំងពីដំបូងរហូតមកទល់នឹងបច្ចុប្បន្ន អង្គជំនុំជម្រះសាលាដំបូងហាក់ដូចជាបានប្រកាន់យកចក្ខុវិស័យនេះ ទោះជានៅក្រោយពេលមានសេចក្តីសម្រេចបំបែកសំណុំរឿងក៏ដោយ។ ជាមួយគ្នានេះ មុនពេលដែលមានការពិភាក្សាថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ ទៅទៀត លោកប្រធានអង្គជំនុំជម្រះ បានប្រកាសជាច្រើនលើក[12] នៅក្នុងអង្គសវនាការថា "*ដើមបណ្តឹងរដ្ឋប្បវេណីអាចលើកឡើងអំពីការឈឺចាប់ដែលខ្លួនមាន អំពីព្យសនកម្មដែលខ្លួនបានទទួលរងក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ដែលគិតចាប់តាំងពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ រហូតដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩។ សូមដើមបណ្តឹង*

[10] Becker, D., Dealing with the consequences of organised violence in trauma work, Berghof Research Center for Constructive Conflict management, edited version 2004, www://www.berghof–handbook.net.

[11] **E124** ដីកាបំបែកសំណុំរឿងដោយអនុវត្តតាមវិធាន ៨៩ ស្ទួនពីរ នៃវិធានផ្ទៃក្នុង។

[12] **E1/25.1** ប្រតិចារិកអង្គសវនាការថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១២ ទំព័រ ៨៧ បន្ទាត់៖១៥-១៧ និង **E1/117.1** ប្រតិចារិកអង្គសវនាការថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ ទំព័រ ៣១ បន្ទាត់៖១២-១៧។ **E1/135.1** ប្រតិចារិកអង្គសវនាការថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ ទំព័រ ៧៤ បន្ទាត់៖១៦-២៤។

*រដ្ឋប្បវេណីទាំងអស់ធ្វើការបង្ហាញអំពីព្យសនកម្មដែលខ្លួនបានទទួលរងនៅក្នុងសម័យកាលដូចបានជម្រាបជូនខាងលើនេះ"* [13]។

១៦. សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីបានកត់សម្គាល់ផងដែរថា គេត្រូវចងចាំថា ដើមបណ្ដឹងរដ្ឋប្បវេណីពុំត្រូវច្រឡំគ្នាជាមួយសាក្សីឡើយ។ ចំណែកឯសក្ខីកម្មរបស់ពួកគេក៏ដូច្នោះ ដែរ។ សក្ខីកម្មរបស់ពួកគេមានទិដ្ឋភាពខាងអង្គហេតុមួយផ្នែក និងមួយផ្នែកទៀតមានលក្ខណៈពិសេសចំពោះជនរងគ្រោះដែលជាដើមបណ្ដឹងរដ្ឋប្បវេណី និងចំពោះភាគីនៃរឿងក្ដី។ ចំពោះលក្ខណៈពិសេសចុងក្រោយនេះ វាពុំមែនជាការណ៍ដែលត្រូវស្ដាប់ធាតុផ្សំនៃភស្តុតាងដែលនឹងបង្កព្យសនកម្មដល់ជនជាប់ចោទទេ។ ដោយមានឱកាសលើកឡើងអំពីការឈឺចាប់របស់ខ្លួន ដើមបណ្ដឹងរដ្ឋប្បវេណីមានឱកាសជាលើកដំបូងក្នុងឆាកជីវិតរបស់ពួកគេ ក្នុងការបង្ហាញជាសាធារណៈ និងចំពោះមុខអង្គជំនុំជម្រះ នូវការឈឺចាប់ដែលខ្លួនបានទទួលរងអស់រយៈពេលជាង ៣០ ឆ្នាំ និងផ្ដល់ជូនអង្គជំនុំជម្រះនូវធាតុផ្សំសំខាន់ សម្រាប់ជាប្រយោជន៍ដល់ការវាយតម្លៃលើអង្គហេតុដើម្បីកំណត់អំពីភាពធ្ងន់ធ្ងរ និងការធ្វើចំណាត់ថ្នាក់អង្គហេតុនោះ។ ក្នុងការលើកឡើងជាលក្ខណៈបុគ្គលអំពីការឈឺចាប់របស់ខ្លួន ដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវបានស្ដាប់ចម្លើយក្នុងអង្គសវនាការ បានបង្ហាញជានិមិត្តរូប នូវសេចក្ដីឈឺចាប់ ខ្លោចផ្សាររបស់ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ ហើយលើសពីពួកគេ គឺរបស់ជនរងគ្រោះទាំងអស់។

១៧. វាជារឿងមួយដែលមានសារៈសំខាន់ក្នុងការអនុញ្ញាតិ្តឱ្យមានពេលវេលាក្នុងការស្ដាប់អំពីភាពឈឺចាប់ នៅពេលដែលគេអនុញ្ញាតឱ្យមានការបំភ្លឺក្នុងវេទិការតុលាការ ពីសំណាក់ជនរងគ្រោះដែលតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនោះ។ គួរកត់សម្គាល់ថា ឱកាសដ៏មានសារៈសំខាន់សម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីនេះ មានរយៈពេលខ្លីប៉ុណ្ណោះក្នុងពេលពិភាក្សាដេញដោល ពោលគឺមានរយៈពេលប្រហែលជា ១៥ នាទី ប៉ុណ្ណោះ សម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ៗ។

១៨. សហមេធាវីនាំមុខ និងសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី សូមរំលឹកថា រហូតមកទល់នឹងពេលបច្ចុប្បន្ននេះ សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងការឈឺចាប់របស់ពួកគេ មានរយៈពេលខ្លី ហើយនៅក្នុងករណីខ្លះ ត្រូវបានតាក់តែងជាលាយលក្ខអក្សរជាមុន ដើម្បីអនុញ្ញាតឱ្យដើមបណ្ដឹង

[13] **E1/117.1** ប្រតិចារិកអង្គសវនាការថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ ទំព័រ ៣១ បន្ទាត់៖១២-១៧។
*សំណើសុំរបស់សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីដើម្បីកំណត់អំពីវិសាលភាពនៃសក្ខីកម្មស្ដីពីការឈឺចាប់របស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលបានដាក់សំណើសុំ*

រដ្ឋប្បវេណីអាចលើកឡើងបានសព្វគ្រប់ដោយនូវអ្វីដែលខ្លួនមានបំណងនិយាយ ដើម្បីកុំឲ្យមានការប៉ះពាល់ផ្នែកអារម្មណ៍ខ្លាំងពេក។ គេពុំអាចបង្រួមសារៈសំខាន់នៃឱកាសនេះ សម្រាប់បុគ្គលដែលពាក់ព័ន្ធ ដែលអាចធ្វើឲ្យពួកគាត់មានការលំបាកក្នុងការថ្លាថ្លែងឲ្យបានស៊ីជម្រៅ និងច្បាស់លាស់ អំពីអ្វីមួយដែលមានសារៈសំខាន់បំផុតក្នុងជីវិតរបស់គាត់នោះឡើយ។ ជាពិសេស សក្ខីកម្មនេះ ទោះបីធ្វើឡើងជាលាយលក្ខអក្សរ ឬពុំមែនលាយលក្ខអក្សរ អាចត្រូវបានតាក់តែងដោយដើមបណ្ដឹងរដ្ឋប្បវេណីជាមួយ និងមេធាវីរបស់ខ្លួន ដូចទៅនឹងអ្វីដែលជនជាប់ចោទអាចមានលទ្ធភាពពិភាក្សាជាមួយមេធាវីរបស់ខ្លួន មុននឹងចូលរួមទៅក្នុងកិច្ចដំណើរនីតិវិធីណាមួយនោះ។

១៩. បុព្វកថានៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាបុព្វកថានៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក. បានលើកឡើងថា "ការព្រួយបារម្ភតាមផ្លូវច្បាប់របស់រដ្ឋាភិបាល និងប្រជាជនកម្ពុជាក្នុងការស្វែងរកយុត្តិធម៌ ការបង្រួបបង្រួមជាតិ ស្ថិរភាព សន្តិភាព និងសន្តិសុខ"។ ក្ដីកង្វល់នេះបានឆ្លើយតបជាពិសេសតាមរយៈការចូលរួមរបស់ជនរងគ្រោះទៅក្នុង ដំណើរការនៃរឿងក្ដីក្នុងឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណី។ វាមានសារៈសំខាន់ទាំងសម្រាប់ប្រជាជនកម្ពុជា ទាំងសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការដែលសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ទាំងសក្ខីកម្មដែលពាក់ព័ន្ធនឹងអង្គហេតុ ទាំងសក្ខីកម្មដែលពាក់ព័ន្ធនឹងការឈឺចាប់ដែលពួកគេបានទទួលរងក្នុងសម័យកាលកម្ពុជាប្រជាធិបតេយ្យ ត្រូវបានដាក់បញ្ចូលទៅក្នុងកិច្ចពិភាក្សាដេញដោល។ នេះជាធាតុផ្សំមួយក្នុងចំណោមធាតុផ្សំទាំងឡាយដែលនាំឲ្យមានយុត្តិធម៌ពេញលេញនៅក្នុងការជំនុំជម្រះក្ដីនេះ។

២០. ក្នុងការផ្សះផ្សារជាតិ មានបង្កប់អត្ថន័យថាទាំងជនរងគ្រោះ និង ជាពិសេសដើមបណ្ដឹងរដ្ឋប្បវេណីមានការពេញចិត្តនឹងដំណើរការនីតិវិធី និងសវនការ។ ដើមបណ្ដឹងរដ្ឋប្បវេណីមានបំណងមុតមាំក្នុងការនិយាយអំពីការឈឺចាប់ដែលពួកគាត់បានទទួលរងអស់រយៈពេល ៣០ ឆ្នាំកន្លងមក។ ដោយហេតុថាគេមិនអាចធ្វើការបែងចែកការឈឺចាប់របស់មនុស្សម្នាក់បាន ដូច្នេះ វាមិនអាចទទួលយកបានទេចំពោះការកំរិតការថ្លែងពីការឈឺចាប់ក្នុងក្របខ័ណ្ឌនៃដំណើរការនីតិវិធីសំណុំរឿង ០០២/០១។

២១. ការកំរិតការថ្លែងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី គឺជាការមិនយកមកពិចារណានូវភាពរងគ្រោះ និងសារៈសំខាន់នៃវិសាលភាពនៃសក្ខីកម្ម សំរាប់ជនរងគ្រោះ និងសាធារណជន។

**ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវតែទទួលបាននូវការគោរពពីសំណាក់ភាគីទាំងអស់**

២២. សហមេធាវីនាំមុខ និងសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី កត់សម្គាល់ឃើញថា យោងតាមសេចក្ដីថ្លែងការណ៍ស្ដីអំពីគោលការណ៍ច្បាប់ជាសារវន្តពាក់ព័ន្ធនឹងជនរងគ្រោះនៃអំពើឧក្រិដ្ឋកម្ម និងជនរងគ្រោះនៃការរំលោភអំណាច "ជនរងគ្រោះត្រូវតែទទួលបាននូវការអាណិតអាសូរ និងការគោរពដល់ភាពថ្លៃថ្នូររបស់ខ្លួន"[14]។

២៣. ចំណុចនេះមានន័យថា រាល់សេចក្ដីជំទាស់ ឬសេចក្ដីអត្ថាធិប្បាយណាមួយដែលប៉ះពាល់ដល់ភាពថ្លៃថ្នូររបស់ដើមបណ្ដឹងរដ្ឋប្បវេណី មិនអាចទទួលយកបានឡើយ។

២៤. ជាទីបញ្ចប់ មេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី និងសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីយល់ឃើញថា សេចក្ដីអត្ថាធិប្បាយដែលធ្វើឡើងពាក់ព័ន្ធទៅនឹងសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីស្ដីអំពីការឈឺចាប់របស់ខ្លួន ពុំមានមូលដ្ឋានសមស្រប និងពុំអាចទទួលយកបានឡើយ។ ប្រសិនណាជាអង្គជំនុំជម្រះចង់អនុញ្ញាតឲ្យមេធាវីការពារក្ដីធ្វើសេចក្ដីអត្ថាធិប្បាយណាមួយនោះ នោះសេចក្ដីអត្ថាធិប្បាយនេះត្រូវតែធ្វើដោយពុំមានវត្តមានរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីជៀសវាងកុំឲ្យដើមបណ្ដឹងរដ្ឋប្បវេណីទទួលរងនូវសំពាធផ្លូវចិត្តបន្ថែមទៀត។

**ហេតុដូច្នេះ សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី និងសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

ក. សូមស្នើដល់អង្គជំនុំជម្រះ មេត្តាបញ្ជាក់អំពីការអនុវត្តជាក់ស្ដែងរបស់អង្គជំនុំជម្រះ ចំពោះបញ្ហាស្ដីអំពីវិសាលភាពនៃការផ្ដល់សក្ខីកម្មពាក់ព័ន្ធនឹងការឈឺចាប់របស់ដើមបណ្ដឹងរដ្ឋប្បវេណី។ ការអនុវត្តដែលតាមរយៈនោះ ដើមបណ្ដឹងរដ្ឋប្បវេណីអាចផ្ដល់សក្ខីកម្មអំពីការឈឺចាប់របស់ខ្លួនបានទាំងមូល និងសព្វជ្រុងជ្រោយក្នុងសំណុំរឿង ០០២។

ខ. សូមស្នើសុំដល់អង្គជំនុំជម្រះ មេត្តារំលឹកថា ដើមបណ្ដឹងរដ្ឋប្បវេណីគួរទទួលបាននូវការគោរព និងមិនត្រូវបានធ្វើឲ្យប៉ះពាល់ដល់ភាពថ្លៃថ្នូររបស់ខ្លួន។

[14] សេចក្ដីសម្រេចលេខ ៤០/៣៤ របស់មហាសន្និបាតអង្គការសហប្រជាជាតិ ឆ្នាំ ១៩៨៥ សេចក្ដីប្រកាសស្ដីអំពីគោលការណ៍ច្បាប់ជាសារវន្តពាក់ព័ន្ធនិងជនរងគ្រោះនៃអំពើឧក្រិដ្ឋកម្ម និងជនរងគ្រោះនៃការរំលោភអំណាច មាត្រា ៤។

គ. ស្នើសុំដល់អង្គជំនុំជម្រះ ប្រសិនណាជាអង្គជំនុំជម្រះអនុញ្ញាតឲ្យមានការធ្វើសេចក្តីអត្ថាធិប្បាយ ពាក់ព័ន្ធទៅនឹងសក្ខីកម្មស្តីអំពីការឈឺចាប់ សេចក្តីអត្ថាធិប្បាយនេះអាចធ្វើឡើងតែក្នុងករណីដែលដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ចប់ការផ្តល់សក្ខីកម្មរបស់ខ្លួន និងបានចាកចេញពីវេទិការផ្តល់សក្ខីកម្ម ក្នុងបន្ទប់សវនាការ។

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១២ | មេធាវី **ពេជ អង្គ**<br>សហមេធាវីនាំមុខ | ភ្នំពេញ | |
| | មេធាវី **Elisabeth SIMONNEAU-FORT**<br>សហមេធាវីនាំមុខ | ភ្នំពេញ | |